ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៩៥
ចុះថ្ងៃទី ២៩-៤-២០១០
សាលដីកា
លេខ: ៥៦ ក្រ៥.ប
ចុះថ្ងៃទី ០៥-៨-២០១៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បានបង្កើតឡើងតាមច្បាប់ ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី២៥-៧-២០១៣ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

- លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

- លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ២៩៥ ចុះថ្ងៃទី ២៩-៤-២០១០ រវាង:

- ជនជាប់ចោទ:

១- ឈ្មោះ [redacted] ៣ភេទប្រុស ជាតិខ្មែរ កើតនៅថ្ងៃខែមិនចាំឆ្នាំ១៩៨៧ កើត និងរស់ [redacted] មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ប្រវត្តិនៃការផ្តន្ទាទោសគ្មាន ឃាត់ខ្លួន ថ្ងៃទី១៧-៥-២០០៨ និងឃុំខ្លួន ថ្ងៃទី១៨-៥-២០០៨ ។

២- ឈ្មោះ [redacted] ភឿន ភេទប្រុស ជាតិខ្មែរ កើតនៅថ្ងៃខែមិនចាំឆ្នាំ ១៩៧៩ កើត និងរស់នៅ [redacted] មុខរបរធ្វើស្រែ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន ៥នាក់ ប្រវត្តិនៃការផ្តន្ទាទោសគ្មាន ឃាត់ខ្លួន ថ្ងៃទី១៧-៥-២០០៨ និងឃុំខ្លួន ថ្ងៃទី១៨-៥-២០០៨ ។

ពីបទ: បង្ករបួសស្នាមដោយចេតនា មានអាវុធ ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៦-៥-២០០៨ ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- ឈ្មោះ [redacted] ភ័ណ្ឌ ភេទប្រុស ជាតិខ្មែរ កើតនៅថ្ងៃខែមិនចាំឆ្នាំ ១៩៨៥ កើត និងរស់នៅភូមិដងអន្ទាក់ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មុខរបរធ្វើស្រែ/



Scanned with CamScanner

ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ២នាក់ ប្រវត្តិនៃការផ្ដន្ទាទោសគ្មាន ឃាត់ខ្លួន ថ្ងៃទី១៧-៥-២០០៨ និងឃុំខ្លួន ថ្ងៃទី១៨-៥-២០០៨ ។

ពីបទ: មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤-៥-២០០៨ ជាបទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] អាយុ៣៣ឆ្នាំ ភេទស្រី មានទីលំនៅសព្វថ្ងៃ [redacted] មុខរបរធ្វើស្រែ ។

- តាមបណ្ដឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី១៨-៨-២០០៩ របស់លោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៣(ក)ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុច សាលក្រមទាំងមូល ។

**ឯរឿងហេតុមានដូចតទៅ:**

កាលពីថ្ងៃទី១៤-៥-២០០៨ វេលាម៉ោង ១៣ ប្ដីនាងខ្ញុំបានសុំលុយនាងខ្ញុំចំនួន ១៥.០០០រៀល ដើម្បីទៅការក្មួយនៅភូមិចំណារចាស់ ឃុំសាលាវិស័យ ហើយគាត់បានផ្ដាំនាងខ្ញុំថា ឯងនៅមើលផ្ទះ មើលកូនផង លុះព្រឹកឡើង នៅថ្ងៃទី១៥-៥-២០០៨ ប្រហែលជាម៉ោង ៦ព្រឹក ឃើញឈ្មោះ ជឿង មកប្រាប់នាងខ្ញុំថា ប្ដីបងឯងគេអាករស្លាប់បាត់ហើយ នាងខ្ញុំក៏ជិះម៉ូតូជាមួយឈ្មោះ ជឿង ទៅមើល ពេលទៅដល់ក៏ឃើញប្ដីនាងខ្ញុំគេអាករដេកស្លាប់ក្បែររបងចិញ្ចើមថ្នល់នៅភូមិចំណារចាស់ ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៣(ក) ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចថា:

១- ផ្ដន្ទាទោសឈ្មោះ [redacted] ភ័ណ្ឌ ហៅ ខ្ញុំ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនទី១៧ ខែឧសភា ឆ្នាំ២០០៨ ពីបទ: អំពើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ ជាបទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២- ផ្ដន្ទាទោសឈ្មោះ [redacted] ភឿន ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនទី១៧ ខែឧសភា ឆ្នាំ២០០៨ តទៅ ពីបទ: បង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ ជាបទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣- ផ្ដន្ទាទោសឈ្មោះ [redacted] ៣៧ ដាក់ពន្ធនាគារកំណត់ ០២ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន ។

ពីបទ: បង្ករបួសស្នាមដោយចេតនា មានអាវុធ ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៨ ជាបទល្មើសដែលមានចែង និងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងបង្គាប់ឲ្យចេញដីកាចាប់ខ្លួនលើឈ្មោះ ពត ៣៧ ។

២៧៥

Scanned with CamScanner

៤- វត្ថុតាងមាន: ឮថៅចំនួន ១, ដាវចំនួន ០២, ដំបងចំនួន ០៤កំណាត់ និងជំពាម កៅស៊ូចំនួន ០១ ត្រូវរឹបអូសបំផ្លាញចោល ។

៥- បង្គាប់ឲ្យឈ្មោះ [redacted] ភ័ណ្ឌ ហៅ ខូ ឈ្មោះ [redacted] គៀន និងឈ្មោះ [redacted] ពៅ រួមគ្នា សងសំណងជំងឺចិត្តចំនួន ១២.០០០.០០០រៀល (ដប់ពីរលានរៀល) ឲ្យទៅតំណាង ជនរងគ្រោះឈ្មោះ [redacted] ម៉ាលីន ទុកឲ្យឈ្មោះ [redacted] ញិប តាមសំណូមពរ ។

៦- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ ហៅ ខូ ឈ្មោះ [redacted] គៀន និង ដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ពៅ តែចំពោះមុខមេធាវី ជនជាប់ចោទ សិទ្ធបើកផ្លូវប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី១៨-៨-២០០៩ របស់លោកព្រះរាជ អាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ នឹងសាលក្រមព្រហ្មទណ្ឌលេខ ៨៣(ក) ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុច សាលក្រមទាំងមូល ។

- បានឃើញ របាយការណ៍រឿង ចុះថ្ងៃទី១៩-៦-២០១០ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍ ។

- បានឃើញ សេចក្ដីសន្និដ្ឋាន ចុះថ្ងៃទី០៩-១១-២០១០ របស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ។

## <u>នាពេលសវនាការ</u>

- ជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ, [redacted] ពៅ, [redacted] គៀន (អវត្តមាន)
- លោក [redacted] ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ (វត្តមាន)
- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ញិប (វត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទ

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ញិប បានឆ្លើយថា ប្ដីខ្លួនជាប្រធានភូមិ នៅពេល ឃើញគេឈ្លោះគ្នា គាត់ក៏ទៅជួយឃាត់ ។ ក្រោយពីឈ្លោះគ្នាបានពីរខែ ក៏មានគេសម្លាប់ ប្ដីខ្លួន មានមនុស្ស ១២ នាក់សម្លាប់ប្ដីខ្លួនដោយអាករ គឺដោយសារការឃាត់មិនឲ្យគេ ឈ្លោះគ្នានេះ ។ ខ្លួនប្ដឹងទាមទារសំណង និងជម្ងឺចិត្តដើម្បីចិញ្ចឹមកូន ។

## <u>តំណាងមហាអយ្យការសន្និដ្ឋានថា:</u>

ការសម្រេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ សុំតម្កល់សាលក្រម ព្រហ្មទណ្ឌលេខ ៨៣(ក) ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកដដែល

## <u>មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋាន:</u>

- លោក [redacted] ចន្ថា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា: សំណូមពរ សុំ តម្កល់សាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ ។

- ក្រោយពីបានស្ដាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី



Scanned with CamScanner

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោ
- ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សាលាឧទ្ធរណ៍យល់ឃើញថា:**

១- បណ្ដឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី១៨-៨-២០០៩ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ ប្ដឹងត្រង់សេចក្ដីសម្រេចទាំងមូលនៃសាលក្រម បណ្ដឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន ។

២- តាមអង្គហេតុករណីឃាតកម្មលើជនរងគ្រោះឈ្មោះ [redacted] មូន នៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤-៥-២០០៨ នោះត្រូវបានសមត្ថកិច្ចនគរបាលយុត្តិធម៌ឃាត់ខ្លួនមនុស្ស ៣នាក់: ១-ឈ្មោះ [redacted] ពៅ, ២-ឈ្មោះ [redacted] ភឿន, ៣- ឈ្មោះ [redacted] ភ័ណ្ឌ ដោយសង្ស័យថា មានការពាក់ព័ន្ធនឹងការស្លាប់ជនរងគ្រោះឈ្មោះ [redacted] មូន ពីព្រោះថ្ងៃកើតហេតុមានសាក្សីមួយចំនួនឃើញក្រុមជនល្មើសប្រដាប់ដោយដាវសាំម៉ូរ៉ៃ ពូថៅ ដំបង អង្កត់អុស ដេញវាយប្រហារមកលើជនរងគ្រោះដោយមិនដឹងមូលហេតុអ្វី សូម្បីតែជនជាប់ចោទចំនួន ០២នាក់ឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] ភឿន ក៏បានឆ្លើយនៅដំណាក់កាលស៊ើបអង្កេតរបស់តុលាការថា ថ្ងៃកើតហេតុពួកគេបានវាយទៅលើជនរងគ្រោះចំចង្កេះ និងចំស្មា ចំខ្នង និងចំដៃផងដែរ ដែលទាំងនេះបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពីរនាក់ខាងលើពុំមែនជាករណីបង្ករបួសស្នាមដោយចេតនាទៅលើជនរងគ្រោះនោះទេ គឺជាអំពើរួមគ្នាធ្វើមនុស្សឃាតដោយចេតនា ហើយសាលាឧទ្ធរណ៍គប្បីដាក់ជនជាប់ចោទទាំង៣នាក់ខាងលើ ឲ្យស្ថិតនៅក្រោមការទទួលខុសត្រូវតាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣- ជនជាប់ចោទឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] ភឿន គប្បីត្រូវបានកែប្រែបទចោទប្រកាន់ពីបទ បង្ករបួសស្នាមដោយចេតនាមានអាវុធ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកជាបទ មនុស្សឃាតដោយចេតនា តាមមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ តាមការយល់ឃើញខាងលើវិញ ។

៤- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ, [redacted] ភឿន និង [redacted] ពៅ ពីបទ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤-៥-២០០៨ តាមមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៤៣(ក) ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការលើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ, [redacted] ភឿន និង [redacted] ពៅ គប្បីសម្រេចជាថ្មីតាមការយល់ឃើញខាងលើ ។



Scanned with CamScanner

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១៩ ចុះថ្ងៃទី១៨-៨-២០០៩ របស់ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តកំពង់ធំ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២- កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] គឿន និង [redacted] ៣៧ ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល មកជាបទ អំពើមនុស្សឃាតដោយចេតនា តាមមាត្រា ៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋវិញ ។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៩៣ (ក) ចុះថ្ងៃទី១៣-៨-២០០៩ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការលើកលែងតែទណ្ឌកម្មលើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ [redacted] គឿន និង [redacted] ៣៧ ត្រូវសម្រេចជាថ្មីថា ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភ័ណ្ឌ [redacted] គឿន និង [redacted] ៣៧ ដាក់ពន្ធនាគារម្នាក់ៗកំណត់ ១២ឆ្នាំ ពីបទ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិចំណារ ឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ កាលពីថ្ងៃទី១៤-៥-២០០៨ តាមបញ្ញត្តិមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។ ក្រៅពីនេះរក្សាទុកដដែល ។

៤- បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

៥- សាលដីកានេះជំនុំជម្រះជាសាធារណៈ ថ្ងៃទី២៥-៧-២០១៣ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ កុល ភ័ណ្ឌ, ជាត គឿន និង ពត ៣៧ និងប្រកាសជាសាធារណៈ ថ្ងៃទី០៥-៨-២០១៣ ។

- បើកផ្លូវប្ដឹងតវ៉ាតាមកំណត់ច្បាប់ ។

សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្តទៅលើឈ្មោះ កុល ភ័ណ្ឌ តែប៉ុណ្ណោះ ក្រៅពីនេះពុំមានអានុភាពទេ ។

សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយ សហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០១..

ក្រឡាបញ្ជី

[redacted]

២៧៨

Scanned with CamScanner